**វត្តពោធិការាម ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា**

80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada

Tel: (613) 230-6268

# ធម៌នមស្សការព្រះរតនត្រ័យពិស្ដារនិងសង្ខេប មានអក្សរខ្មែរប្រកបជាសំនៀងបាលីភាសា សំរាប់ជំនួយដល់អ្នកមិនចេះអានបាលីដំបូង

ខ្ញុំនឹងសង្ឃឹមនូវអស់លោក ដែលមានវិយោគ [(១)] មកច្រើននេះ
សន្សំនូវចិត្តហើយត្រិះរិះ ទុកជាជំនិះសំរាប់ឆ្លង ។
ព្រោះខំកសាងយ៉ាងយូរក្រៃ ពិនិត្យរាល់ថ្ងៃឥតមានហ្មង
ឥឡូវកើតមកមានតែម្ដង សូមឱ្យញាតិផងប្រឹងរក្សា ។
សត្វឯណាមួយបានស្វែងរក ហើយចេះលៃលកដល់សត្ថា
ទុកដូចជាស្ពានអម្បាយា ឱ្យសត្វមេត្តាគ្រប់វេលា ។

---

១- ពាក្យថា " **វិយោគ**" ការព្រាត់ប្រាស, ចាកបុគ្គលឬអ្វី១ដែលធ្លាប់ស្រឡាញ់ពេញចិត្ត និង សំរាប់សាកលោកផង ឥតមានរបស់អ្វីទៀងនោះផងដែរ ហើយវាមានដី ទឹក ភ្លើង ខ្យល់ ធាតុទាំង ៤ នេះ មានគ្រប់មនុស្ស សត្វទាំងឡាយ កាលណាបើគ្មានធាតុទាំង ៤ នេះទេ មនុស្សក្ដី សត្វក្ដី រស់នៅដោយវេទនា ដោយសាអ្វី គឺការខ្វះធាតុទាំង ៤ នេះ, ឧទាហរណ៍ថា បើបាត់ធាតុខ្យល់ ឬ ធាតុខ្យល់នោះមានការស្ទះ ចំពោះអការៈណាមួយ ក៏ធ្វើឱ្យមនុស្សនោះមានការ រងទុក្ខលំបាកដល់រាងកាយទាំងមូល ។

# វត្តពោធិការាម ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា

80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada
Tel: (613) 230-6268.

## ពាក្យប្រារព្ធ

ដោយយល់ឃើញថា ពុទ្ធបរិស័ទខ្មែរមួយចំនួនពុំទាន់បានចេះចាំធម៌មនស្សការព្រះរតនត្រ័យនេះ ទើបអាត្មាភាពបានរៀបចំជាសៀវភៅធម៌ថ្វាយបង្គំនេះឡើង ដើម្បីបំពេញបំណងពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លាចង់ចេះចាំនូវធម៌មនស្សការ សំរាប់សូត្រនៅពេលមានកម្មវិធីបុណ្យនានា ឬ សូធ្យថ្វាយបង្គំព្រះរតនត្រ័យនៅតាមគេហដ្ឋាន ជាការសន្សំនូវឧបនិស្ស័យក្នុងព្រះពុទ្ធសាសនានិងញ៉ាំងអានិសង្សនៃបុណ្យឱ្យកើតឡើងក្នុងសន្តានចិត្តរបស់សត្វទាំងឡាយ និង សូមឱ្យមានសេចក្តីសុខ ទាំងបច្ចុប្បន្នភពនិងសម្បរាយភព ។

សៀវភៅនេះ អាត្មាភាព បានសរសេររបៀបអានជាសំនៀងបាលីភាសា ដោយប្រើអក្ខរៈខ្មែរប្រកបនៅពីក្រោមបាលីភាសាផង ដើម្បីជំនួយដល់អស់លោកអ្នកពុទ្ធបរិស័ទគ្រប់ស្រទាប់ និង គ្រប់វ័យដែលមិនចេះអាននូវបាលីភាសានេះ ហើយអាចអានបាននិងសូធ្យបានតាមបំណងរបស់ខ្លួន ។

សូមបញ្ជាក់ថា អក្ខរៈខ្មែរដែលប្រកបជាសំនៀងបាលីនោះដូចជាពាក្យថា **ពុទ្ធំ សរណំ គច្ឆាមិ** (**ពុទ្ធំ**= ពុតធាំង, **សរណំ**= សៈរ៉ៈណាំង, **គច្ឆាមិ**=គ័ចឆ្ចាមិ) ដូច្នេះជាដើម អាត្មាភាព សរសេរឡើងគ្រាន់តែយកសំនៀងតាមបាលី ឱ្យអ្នកដែលមិនចេះអានបាលីនោះហើយអាចអានបានផង ប៉ុន្តែលក្ខណៈនៃការប្រកបនេះមិនត្រូវបានគេយកជាផ្លូវការនោះទេ ។ បើមានការខុសឆ្គងយ៉ាងណានោះ ក៏សូមឱ្យវិទូទាំងឡាយ មេត្តាជួយសំរួលនិងខន្តីនូវទោសានុទោសចែកខ្ញុំព្រះករុណា-អាត្មាភាពផង ។

ដោយគុណានុភាពនៃព្រះរតនត្រ័យនេះ សូមឱ្យសត្វទាំងឡាយ បានសន្តិភាពកើតមានក្នុងមនោគតិរបស់សត្វទាំងអស់ឱ្យបានគ្រប់ៗរូបកុំបីឃ្លៀងឃ្លាតជាបការៈដទៃឡើយ ។

វត្តពោធិការាម ពុទ្ធិកសមាគមខេមរមណ្ឌល អូត្តាវ៉ា
80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada

# ត្រៃប្រណាម

អ្នកឯណាមួយ ដែលជាអ្នកមានបសាទសទ្ធាគឺសេចក្តីជ្រះថ្លាជឿគុណព្រះរតនត្រ័យ ប្រកបដោយឧស្សន្នកុសលចេតនា គឺចេតនាជាកុសលកើតឡើងប្រាថ្នាប្រារព្ធ ដើម្បីនមស្ការថ្វាយបង្គំព្រះរតនត្រ័យនោះ កាលមុននឹងនមស្សការថ្វាយបង្គំ ក៏តាំងចេតនារបស់ខ្លួនឱ្យជ្រះថ្លាផូរផង់ឡើង ។

ដោយអំណាចធម្មទានានិសង្សនេះ សូមផ្សាយបុញ្ញរាសី ដល់ពុទ្ធសាសនិកជនទាំងឡាយ ចូរឱ្យបានប្រកបដោយសេចក្តីសុខ និង សេចក្តីចំរើនគ្រប់ប្រការឱ្យបានសព្វៗកាលទៅហោង ។

**♠ ថ្ងៃ ៥ កើត ខែមាឃ ឆ្នាំច អដ្ឋស័ក ព-ស ២៥៥០**

**ថ្ងៃអង្គារទី ២៣ ខែមករា គ-ស ២០០៧**

*Tuesday January 23, 2007*

រៀបរៀងធម៌នមស្សការនេះដោយ

**ភិក្ខុតិក្ខមុនី អ៊ុំ ឆេង**

*Bhikkhu Tikkhamuny Chhheng Oum*

បុគ្គលពាលទាំងឡាយមិនសរសើរនូវទានឡើយ

THE MONDUL OTTAWA KHMER
BUDDHIST MONASTERY

LE MONASTERE DES BOUDDHISTES
KHMERS DE MONDUL OTTAWA

# វត្តពោធិការាម

80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada
Tel: (613) 230-6268

---

# ធម៌នមស្សការព្រះរតនត្រ័យពិស្តារនិងសង្ខេប

# មានអក្សរខ្មែរប្រកបជាសំនៀងបាលីភាសា

# សំរាប់ជំនួយដល់អ្នកមិនចេះអាននូវបាលីដំបូង

# មានឌីសជាសំលេងធម៌សំរាប់ស្តាប់

# និង

# ចែកជាធម្មទាន

# ចិត្តវិបុលំ

ចិត្តទូលាយស្ពាយសេចក្តីសុខ ប្រមូលញាតិទុកសុខសន្តិភាព រៀបទូទៅនៅជិតឆ្ងាយ
សប្បាយទាំងអស់ស្មោះចូលជួយ គ្រាន់បានជំនួយស្ទួយសាសនា ព្រោះមនុស្សកើតមកក្នុងលោកា
ដែលព្រះសាស្តាលោកបានសម្តែង ។

80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada

# របៀបរៀនអានបាលីភាសាជាដំបូង

## អក្ខរវិធី

## អក្ខរៈក្នុងបាលីភាសាទាំងអស់មាន ៤១ តួគឺៈ

### ស្រៈនិស្ស័យនិងស្រៈពេញតួ

**អ** = (អៈ)

**អា** = (អា)

**ឥ** = អ៊ិ

**ឦ** = អ៊ី

**ឧ** = អ៊ុ

**ឩ** = អ៊ូ

**ឯ** = អេ

**ឱ** = (អោ) ៨ តួនេះហៅថា **សរៈ** (ស្រៈ) ។

## ព្យញ្ជនក្នុងបាលីភាសាមាន ៣៣ តួគឺៈ

**ក** = (កៈ), **ខ** = (ខៈ), **គ** = (គៈ), **ឃ** = (ឃៈ), **ង** = (ងៈ),

**ច** = (ចៈ), **ឆ** = (ឆៈ), **ជ** = (ជៈ), **ឈ** = (ឈៈ), **ញ** = (ញៈ),

**ដ** = (ដៈ), **ឋ** = (ឋៈ), **ឌ** = (ឌ), **ឍ** = (ឍៈ), **ណ** = (ណៈ),

**ត** = (តៈ), **ថ** = (ថៈ), **ទ** = (ទៈ), **ធ** = (ធៈ), **ន** = (នៈ),

**ប** = (បៈ), **ផ** = (ផៈ), **ព** = (ពៈ), **ភ** = (ភៈ), **ម** = (មៈ),

**យ** = (យៈ), **រ** = (រៈ), **ល** = (លៈ), **វ** = (វៈ), **ស** = (សៈ), **ហ** = (ហៈ), **ឡ** = (ឡៈ), **O** = (អាំង) ៣៣ តួនេះហៅថា ព្យញ្ជនៈ ។

80 Preston St., Unit # 1, Ottawa, Ontario, K1R 7N9, Canada

## ពិធីផ្សំស្រះ និង ព្យញ្ជនៈ

## ដោយសង្ខេប និង ឧទាហរណ៍

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ។

**អហំ**[១] = ( អះហាំង) ខ្ញុំព្រះករុណា

**គច្ឆាមិ** = ( គ័ចច្ឆាមិ) សូមដល់

**ពុទ្ធំ** = (ពុតធាំង)នូវព្រះពុទ្ធ

**សរណំ** = ( សះរ៉ះណាំង) ជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធមិ[២] ជាទីពឹងទីរលឹក ។

**អហំ** = ( អះហាំង) ខ្ញុំព្រះករុណា

**គច្ឆាមិ** = ( គ័ចច្ឆាមិ) សូមដល់

**ធម្មំ** = ( ធាំមាំង) នូវព្រះធមិ

**សរណំ** = ( សះរ៉ះណាំង) ជាទីពឹងទីរលឹក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ។

**អហំ** = ( អះហាំង) ខ្ញុំព្រះករុណា

**គច្ឆាមិ** = ( គ័ចច្ឆាម) សូមដល់

**សង្ឃំ** = ( សាំងឃាំង) នូវព្រះសង្ឃ

**សរណំ** = ( សះរ៉ះណាំង) ជាទីពឹងទីរលឹក ។

---

១- ត្រង់ពាក្យថា " **អហំ** " គឺជាបប្រធាននៅខាងក្រៅប្រយោគនេះ ព្រោះកិរិយាស័ព្ទរបស់ប្រធាននោះគឺ **គច្ឆាមិ** នេះឯង ។

២- ត្រង់ពាក្យថា " ធមិ " នេះគឺជាពាក្យសំស្ក្រឹត បើបាលីភាសាវិញគឺ " ធម្ម " ប្រែថា: សភាវៈ ទ្រទ្រង់សត្វលោក, បុណ្យ, បាប, សុចរិត, ហេតុ, ទុច្ចរិត, សភាព, ប្រាជ្ញាញាណ, គុណ, សេចក្តីចំរើន, ការរិះគិត, សង្ខារ ។

# ធម៌នមស្ការព្រះរតនត្រ័យសង្ខេប

## បូជាព្រះរតនត្រ័យ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ**

អ៊ិមេហ៊ិ ទីប៉ៈធូប៉ាទិស័កការេហ៊ិ ពុតធាំង ធាំម៉ាំង សាំងឃាំង អៈភ៊ិបូជៈយាមិ

**មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ**

មាតាប៊ិតាទីណាំង គុណៈវ័នតាណាញ៉ូចៈ ម៉ៃហាញ៉ូចៈ ទីឃៈរ៉ាត់តាំង អាត់ថាយៈ

**ហិតាយ សុខាយ ។**

ហ៊ិតាយៈ សុខាយៈ ។

*ប្រែថា:* ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

## ពុទ្ធរតនប្បណាម

### ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

នៈមោ តៈសាក់ ភៈគៈវ៉ៈតោ អៈរ៉ៈហៈតោ សាំម៉ាសាំពុតធៈសៈ ។

*ប្រែថា:* វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ *សូធ្យបាលី ៣ ចប់ ឯសំរាយសូធ្យតែ១ចប់បាន* ។

**រួចហើយគប្បីតាំងចិត្តរឭកដល់ពុទ្ធគុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា**

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ**

អ៊ិតិប៊ិ សោ ភៈគៈវ៉ា អៈរ៉ៈហាំង សាំម៉ាសាំពុតថូ

**វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ**

វិជ្ជាចៈរ៉ៈណៈសាំប៉ាន់ណោ សុគៈតោ លោកៈវិទូ អៈនុតតៈរ៉ោ

**បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

ប៉ុរិសៈទាំមៈសារៈថិ សាត់ថា ទេវៈមៈនុស្សាណាំង ពុតថូ ភៈគៈវ៉ាតិ ។

**តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច**

តាំង អៈរ៉ៈហាទិគុណៈសាំងយុតតាំង ពុតធាំង សិរ៉ៈសា នៈមាមិ តាញ់ចៈ

**ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ពុតធាំង អុិមេហិ ស័កការេហុិ អៈភិប៉ូជៈយាមិ ។

**ក្រាបថ្វាយបង្គំម្តង**

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**

ស្វ៉ាកខាតោ ភៈគៈវ៉ៈតា ធាំម៉ូ សន់ទិតថិកោ អៈកាលិកោ

**ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**

អេហុិប៉ះសិកោ អោប៉ាក់ណៈយិកោ ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញ្ញូហីតិ ។

**តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច**

តាំង ស័កខាតាទិគុណៈសាំងយុតតាំង ធាំមាំង សិរ៉ៈសា នៈមាមិ តាញ់ចៈ

**ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ធាំមាំង អុិមេហិ ស័កការេហុិ អៈភិប៉ូជៈយាមិ ។

**(ក្រាបថ្វាយបង្គំម្តង)**

## សង្ឃរតនប្បណាម

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

សុបៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ

**ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ**

ឧជុបះដិប៉ាន់ណោ ភះគះវះតោ សាវះកះសាំងខូ

**ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ**

ញាយះបះដិប៉ាន់ណោ ភះគះវះតោ សាវះកះសាំងខូ

**សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ**

សាម៉ីចិបះដិប៉ាន់ណោ ភះគះវះតោ សាវះកះសាំងខូ

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស**

យះទិទាំង ចាត់តារិ ប៉ុរិសះយុគានិ អាត់ថះ ប៉ុរិសះប៉ុកគះលា អេសះ

**ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ**

ភះគះវះតោ សាវះកះសាំងខូ អាហ៊ុណេយ៉ោ ប៉ាហ៊ុណេយ៉ោ

**ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ**

ទ័កខិណេយ៉ោ អាញ់ជះលិកៈរ៉ះណីយ៉ោ អះនុតតះរ៉ាំង

**បុញ្ញក្ខេត្តំ លោកស្សាតិ ។**

ប៉ុញញោក់ខេតតាំង លោកះសាតិ ។

**តំ សុប្បដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច**

តាំង សុប៉ះដិប៉ាន់ណាទិគុណះសាំងយុតតាំង សាំងឃាំង សិរ៉ះសា នះមាមិ តាញ់ចះ

**សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

សាំងឃាំង អ៊ិមេហិ ស័កការេហ៊ិ អះភិប៉ូជះយាមិ ។

**(ក្រាបថ្វាយបង្គំម្តង)**

## នមស្សការព្រះសក្យមុនីចេតិយ

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេ សុប្បតិដ្ឋិតំ**

វ៉ាន់ទាមិ ចេតិយ៉ាំង សាប់ពាំង សាប់ព័តថានេ សុបះតិតថិតាំង

# សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។

សារីរិកៈធាតុ- មៈហាពោធឹង ពុតធៈរូប៉ុង សៈកៈឡាំង សៈទា ។

*ប្រែថា:* ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ ព្រមទាំងព្រះសារីរិក-ធាតុនៃព្រះពុទ្ធ
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត លំអោនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលឋិតនៅគ្រប់ទិសទី ឋាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។
សូមទាន់ព្រះអរិយ- មេត្រីថ្លៃវិសិដ្ឋ សូមបានឃើញធមិពិត សមដូចចិត្តប្រាថ្នាហោង ។

**(ក្រាបថ្វាយបង្គំម្តង)**

## ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ

អ៊ិចចេវៈម៉ាច់ច័នតៈ នៈម៉ះសៈណីយាំង នៈម៉ះសៈម៉ាណោ រៈតៈន័តយាំង យាំង

## បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ

ប៉ុញញ៉ាភិស័នទាំង វិប៉ុឡាំង អៈឡាត់ថាំង តះសានុភាវេនៈ ហៈត័នតៈរ៉ាយ៉ោ ។

ប្រែថា:
ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល អោយបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមអោយកំចាត់បង់ អពមង្គលទាំងឡាយ
អោយចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកំលាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វាហោង ។

# បាលីសមាទានសីល៥

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន**
អ៊ុកាសះ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ តិសៈរ៉ៈណេនៈ
**សហ បញ្ចសីលានិ យាចាម ។**
សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
ទុតិយ៉ាំបុិ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ
**តិសរណេន សហ បញ្ចសីលានិ យាចាម ។**
តិសៈរ៉ៈណេនៈ សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។
**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន**
ទុតិយ៉ាំបុិ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ តិសៈរ៉ៈណេនៈ
**សហ បញ្ចសីលានិ យាចាម ។**
សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។

*ត្រង់ពាក្យថា:* **( អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ)**
អៈនុកគៈហាំង ក័តត្វា សីឡាំង តេថៈ ណូ ភ័នតេ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ ដង) ។

♠ **ទទួលព្រៃសរណគមន៍ ពីព្រះសង្ឃដូច្នេះគឺៈ**

**ពុទ្ធំ សរណំ គច្ឆាមិ** (ពុតធាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**ធម្មំ សរណំ គច្ឆាមិ** (ធាំមាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**សង្ឃំ សរណំ គច្ឆាមិ** (សាំងឃាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (ទុតិយាំប៉ិ ពុតធាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (ទុតិយាំប៉ិ ធាំមាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (ទុតិយាំប៉ិ សាំងឃាំង សៈរ៉ៈណាំង គ័ចច្ឆាមិ) ។
**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (តៈតិយាំប៉ិ ពុតធាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (តៈតិយាំប៉ិ ធាំមាំង សៈរ៉ៈណាំង គ័ចច្ឆាមិ)
**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (តៈតិយាំប៉ិ សាំងឃាំង សៈរ៉ៈណាំង គ័ចច្ឆាមិ) ។

( ***តិសរណគ្គហនំ បរិបុណ្ណំ*** បាលីខ្លីនៅក្នុងរង្វង់ក្រចកនេះ ព្រះសង្ឃលោកស្វាធ្យាយទេ)

*ត្រង់នេះឧបាសក-ឧបាសិកា-ទាយក-ទាយិកា ទទួលឆ្លើយពីលោកថា* **អាម ភន្តេ** ( អាមៈ ភ័នតេ)

**តទៅនេះនឹងទទួលសីល ៥**

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**
ប៉ាណាតិប៉ាតា វេរ៉ៈមៈនី សិក្ខាប៉ះទាំង សៈម៉ាទិយាមិ

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**
អៈទិននាទានា វេរ៉ៈមៈនី សិក្ខាប៉ះទាំង សៈម៉ាទិយាមិ

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**
កាមេសុមិចឆាចារ៉ា វេរ៉ៈមៈនី សិក្ខាប៉ះទាំង សៈម៉ាទិយាមិ

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**
មុសាវ៉ាទា វេរ៉ៈមៈនី សិក្ខាប៉ះទាំង សៈម៉ាទិយាមិ

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**
សុរាមេរ៉ៈយៈម៉ាច់ជាប់ប៉ៈម៉ាទាត់ថាណា វេរ៉ៈមៈនី សិក្ខាបៈទាំង សៈម៉ាទិយាមិ

**ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។** (*ឧបាសក-ឧបាសិក-ទាយក-ទាយិកា ត្រូវទទួលថា* **អាម ភន្តេ**)

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ฯ**

*ត្រូវទទួល អនុមោទនាថា* **សាធុ** *បីដង*

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេយោ ខលិតោ**

អ៊ុតតៈម៉ាំងកេនៈ វ៉ៃនតេហាំង ប៉ាទៈប៉ុងសុង វៈរុតតៈម៉ាំង ពុតថេយ៉ូ ខៈលិតោ

**ទោសោ ពុទ្ធោ ខមតុ តំ មមំ ฯ**

តូសោ ពុតថូ ខៈមៈតុ តាំង មៈម៉ាំង ។

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេយោ ខលិតោ**

អ៊ុតតៈម៉ាំងកេនៈ វ៉ៃនតេហាំង ធាំម៉ាញ់ចៈ ទុវិធាំង វៈរ៉ាំង ធាំម៉េយ៉ូ ខៈលិតោ

**ទោសោ ធម្មោ ខមតុ តំ មមំ ฯ**

តូសោ ធាំម៉ូ ខៈមៈតុ តាំង មៈម៉ាំង ។

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេយោ ខលិតោ**

អ៊ុតតៈម៉ាំងកេនៈ វ៉ៃនតេហាំង ស័ងខ័ញចៈ ទុវិធោតតៈម៉ាំង សាំងខេយ៉ូ ខៈលិតោ

**ទោសោ សង្ឃោ ខមតុ តំ មមំ ฯ**

តូសោ សាំងខូ ខៈមៈតុ តាំង មៈម៉ាំង ។

## សូត្រសូមខមាទោសសង្ខេបបែបសម្រាយ

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

## គាថាសុំនូវសេចក្តីសុខ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញ្ញ៉ុំង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ សាសៈណាំង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញ្ញ៉ុំង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ រាជាណូ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញ្ញ៉ុំង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ញាតៈយ៉ោ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញ្ញ៉ុំង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ប៉ាណិណោ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញ្ញ៉ុំង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ណូ សៈទា ។

## ធម៌តាំងសេចក្តីប្រាថ្នានិងឧទ្ទិសផល

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា ពោលគឺនិព្វាន ។ គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន ដល់ឋានថ្លៃថ្លា ។ សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧបជ្ឈា-យាចារ្យ គុណញាតកា ប្រាំពីរសន្តាន ។ ជីនដូនជីតា រស់នៅក្តីណា លោកម្ចាស់ឋាន សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត ដល់ឋានផុតទុក្ខ ។ ខ្ញុំសូមប្រាថ្នា សច្ចៈវាចា តទៅខាងមុខ សូមមានបញ្ញា ភ្លឺថ្លាមោះមុត ឆ្លងរួចផុតទុក្ខ ដល់និព្វានហោង ។

## បត្តិទានគាថា

## ធម៌ឧទ្ទិកុសល

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា**
យ៉ាំង កិញ្ចិ កុសះលះកាំម៉ាំង កាត់ត័បពាំង កិរិយ៉ាំង មះមះ កាយេនះ វាចា

**មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ**
មះនះសា តិទះសេ សុគះតាំង កះតាំង យ៉េ ស័តតា សាញ់ញិណោ អ័តថិ

**យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ**
យ៉េ ចះ ស័តតា អះសាញ់ញិណោ កះតាំង ប៉ុញញ៉ៈផះឡាំង ម៉ៃហាំង ស័ប‌ប៉េ

**ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ**
ភាគី ភះវ៉ន្តុ តេ យ៉េ តាំង កះតាំង សុវិទិតាំង ទិនណាំង ប៉ុញញ៉ៈផះឡាំង

**មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ**
មះយា យ៉េ ចះ តាត់ថះ នះ ជាណន់តិ ទេវ៉ា គាន់ត្វា និវេទះយុង

**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា**
ស័បប៉េ លោកាំហិ យ៉េ ស័តថា ជីវ៉ានតាហារះហេ តុកា

**មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**
មះនុញញ៉ាំង ភោជះណាំង ស័បប៉េ លះភ័នតុ មះមះ ចេតះសាតិ ។

**ចប់ធម៌នមស្សការព្រះរតនត្រ័យសង្ខេបតែប៉ុណ្ណេះ**

# ធម៌នមស្សការព្រះរតនត្រ័យពិស្តារ

## បូជាព្រះរតនត្រ័យ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ**

អ៊ិមេហ៊ិ ទីប៉ះធូប៉ាទិស័កការេហ៊ិ ពុតធាំង ធាំមាំង សាំងឃាំង អៈភុបូជៈយាមិ

**មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ**

មាតាប៊ិតាទីណាំង គុណៈវ័នតាណាញ់ចៈ ម៉ៃហាញ់ចៈ ទីឃៈរ៉ាត់តាំង អាត់ថាយៈ

**ហិតាយ សុខាយ ។**

ហិតាយៈ សុខាយៈ ។

ប្រែថា: ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

## ពុទ្ធរតនប្បណាម

### ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

នៈមោ តះសាក់ ភៈគៈវៈតោ អៈរ៉ៈហៈតោ សាំម៉ាសាំពុតធះសៈ ។

ប្រែថា: វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ *សូធ្យបាលី ៣ ចប់ ឯសំរាយសូធ្យតែ១ចប់បាន* ។

♠ មហាករុណា នាំឱ្យមានសេចក្តីសុខសាន្ត ។ បុគ្គលសុខសាន្ត នាំឱ្យគ្រួសារសុខសាន្ត ។ គ្រួសារសុខសាន្ត នាំឱ្យសហគមន៍សុខសាន្ត ។

*Great comppassion makes a peaceful heart. A peaceful person makes a peaceful family. A peaceful family makes a peaceful community.*

**យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ**

យ៉ូ សន់និសន់ណោ វ៉ៈរ៉ៈពោធិម៉ូលេ មារ៉ាំង សៈសេណាំង មៈហៈតឹង

**វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ**

វិជ័យយ៉ូ សាំពោធិមាគ័ចឆិ អៈណន់តៈញាណោ លោកុតតៈម៉ោ

**តំ បនមាមិ ពុទ្ធំ ។**

តាំង បៈនៈម៉ាមិ ពុតធាំង ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

យ៉េ ចៈ ពុតធា អៈតីតា ចៈ យ៉េ ចៈ ពុតធា អៈណាគៈតា

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា**

ប៉ាច់ចុបប៉ាន់ណា ចៈ យ៉េ ពុតធា អៈហាំង វ័នទាមិ ស័បពៈទា ។

## ក្រាបថ្វាយបង្គំម្តង

រួចហើយគប្បីតាំងចិត្តរឭកដល់ពុទ្ធគុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ**

អ៊ិតិប៉ិ សោ ភៈគៈវ៉ា អៈរ៉ៈហាំង សាំម៉ាសាំពុតថូ

**វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ**

វិជ្ជាចៈរ៉ៈណៈសាំប៉ាន់ណោ សុគៈតោ លោកៈវិទូ អៈនុតតៈរ៉ោ

**បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

ប៉ុរិសៈទាំមៈសារៈថិ សាត់ថា ទេវៈមៈនុស្សាណាំង ពុតថូ ភៈគៈវាតិ ។

**តទៅនេះប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា**

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

ណាត់ថិ មេ សៈរ៉ៈណាំង អាញ់ញាំង ពុតថូ មេ សៈរ៉ៈណាំង វ៉ៈរ៉ាំង

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

អេតេនៈ សាច់ចៈវេជជេនៈ ហោតុ មេ ជៈយៈម៉ាំងគៈលាំង ។

**ប្តេជ្ញាដូច្នេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ**

អ៊ុតតៈម៉ាំងគេនៈ វ៉័នតេហាំង ប៉ាទៈប៉ុំងសុំង វៈរ៉ុតតៈម៉ាំង ពុតថេ យ៉ូ

**ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

ខៈលិតោ តូសោ ពុតថូ ខៈមៈតុ តាំង មៈម៉ាំង ។

**ក្រាបថ្វាយបង្គំម្តង**

**ធម្មរតនប្បណាម**

**ថ្វាយបង្គំព្រះធម្មរតនៈ**

**អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច**

អាត់ថាំងគិការីយៈបៈថោ ជៈនាណាំង ម៉ោកខាប់បៈវេសាយៈ អ៊ុជូ ចៈ

**មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ**

ម័កគោ ធាំម៉ូ អៈយ៉ាំង សន់តិកៈរ៉ោ បៈណីតោ ន័យយានិកោ តាំង

**បនមាមិ ធម្មំ ៚**

បៈនៈម៉ាមិ ធាំម៉ាំង ។

**ក្រាបថ្វាយបង្គំម្តង**

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

យ៉េ ចៈ ធាំមា អៈតីតា ចៈ យ៉េ ចៈ ធាំមា អៈណាគៈតា

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ៚**

ប៉ាច់ចុបប៉ាន់ណា ចៈ យ៉េ ធាំមា អៈហាំង វ៉័នទាមិ ស័បពៈទា ។

រួចហើយគប្បីតាំងចិត្តរឭកដល់ធម្មគុណដោយបង្អោនកាយវាចាចិត្តថា

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**

ស្វ៊កខាតោ ភៈគៈវ៉ៈតា ធាំម៉ូ សន់ទិតថិកោ អៈកាលិកោ

**ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**

អេហិប៉ះសិកោ អោប៉ាក់ណៈយិកោ ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញ្ញូហីតិ ។

តទៅគប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

ណាត់ថិ មេ សៈរ៉ៈណាំង អាញ់ញ៉ាំង ធាំម៉ូ មេ សៈរ៉ៈណាំង វ៉ៈរាំង

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ៗ**

អេតេនៈ សាច់ចៈវេជជេនៈ ហោតុ មេ ជៈយៈម៉ាំងគៈល៉ាំង ។

ប្តេជ្ញាខ្លួនដូច្នេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះធម៌ជាម្ចាស់ថា

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ**

អ៊ុតតៈម៉ាំងគេនៈ វ៉ាន់តេហាំង ធាំម៉ាញ់ចៈ ទុវិធាំង វ៉ៈរ៉ាំង ធាំមេ យ៉ូ

**ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ៗ**

ខៈលិតោ តូសោ ធាំម៉ូ ខៈមៈតុ តាំង មៈម៉ាំង ។

## សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ**

សាំងខូ វិសុតថូ វ៉ៈរ៉ៈទ័កខិណៃយ៉ោ សន់តិណទ្រិៈយ៉ូ

**សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ**

ស័បពៈមៈលាប់បៈហីណោ គុណេហិណេកេហិ សៈមិតធិប៉ាត់តោ

**អនាសវោ តំ បនមាមិ សង្ឃំ ៕**

អៈណាសៈវ៉ោ តាំង បៈនៈម៉ាមិ សាំងយាំង ។

**(ក្រាបថ្វាយបង្គំម្តង)**

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

យ៉េ ចៈ សាំងយា អៈតីតា ចៈ យ៉េ ចៈ សាំងយា អៈណាគៈតា

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ៕**

ប៉ាច់ចុបប៉ាន់ណា ចៈ យ៉េ សាំងយា អៈហាំង វ៉ៃនទាមិ ស័បពៈទា ។

**(ក្រាបថ្វាយបង្គំម្តង)**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

សុបៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

ឧជុបៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

ញាយៈបៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

សាមុីចិបៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស**

យៈទិទាំង ចាត់តារិ ប៉ុរិសៈយុគានិ អាត់ថៈ ប៉ុរិសៈប៉ុកគៈលា អេសៈ

**ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ**

ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងខូ អាហ៊ុណើយ៉ោ ប៉ាហ៊ុណើយ៉ោ

**ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ**

ទ័កខិណើយ៉ោ អាញ់ជៈលិកៈរ៉ៈណើយ៉ោ អៈនុតតៈរ៉ាំង

# បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប៉ុញញាក់ខេតតាំង លោកះសាតិ ។

**វេចកផលសង្ឃគុណធម្មទ្រេះរួចហើយ គប្បីប្រកាសថ្លែថ្វាខ្លួនដោយពាក្យសច្ចៈថា**

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**

ណាត់ថិ មេ សៈរ៉ៈណាំង អាញ់ញ៉ាំង សាំងឃូ មេ សៈរ៉ៈណាំង វ៉ៈរ៉ាំង

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

អេតេនៈ សាច់ចៈវេជជេនៈ ហោតុ មេ ជៈយៈម៉ាំងគៈលាំង ។

**ថ្លែថ្វាខ្លួនធម្មទ្រេះរួចហើយ គប្បីសូត្រសូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ថា**

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ**

អ៊ុតតៈម៉ាំងកេនៈ វ៉ាន់តេហាំង សាំងខាញ់ចៈ ទុវិធូតតៈម៉ាំង សាំងខេ

**យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

យ៉ូ ខៈលិតោតូសោ សាំងឃូ ខៈមៈតុ តាំង មៈម៉ាំង ។

**នមស្សការព្រះសក្យមុនីចេតិយ**

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេ សុបតិដ្ឋិតំ**

វ៉ាន់ទាមិ ចេតិយ៉ាំង សាប់ពាំង សាប់ព័តថានេ សុបៈតិតថិតាំង

**សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

សារីរិកៈធាតុ- មៈហាពោធឹង ពុតធៈរូប៉ុង សៈកៈឡាំង សៈទា ។

<u>ប្រែថា:</u> ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ ព្រមទាំងព្រះសារីរិក-ធាតុនៃព្រះពុទ្ធ និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត លំអោនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។

និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលឋិតនៅគ្រប់ទិសទី ឋាននានានោះទាំងអស់ ។

ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ ។

សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។

សូមទាន់ព្រះអរិយ- មេត្រីថ្លៃវិសិដ្ឋ សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

## ពុទ្ធបាទនមក្ការគាថា

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ**

វ៉ន្ទាមិ ពុតធាំង ភ:វ:ប៉ា:តិណណាំង តិលោក:កេតុង តិភ:វេក:នាថាំង

**យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន**

យ៉ូ លោក:សេតថោ ស:ក:ឡាំង កិលេសាំង ឆេត្វាន:

**ពោធេសិ ជនំ អនន្តំ ។**

ពោធេសិ ជ:ណាំង អ:ណន់តាំង ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

យ៉ាំង ណាំម:ទាយ: ន:ទិយា ប៉ុលិណេ ច: តីរ៉េ

**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**

យ៉ាំង សាច់ច:ព័នធ:គិរិកេ សុម:នាច:ល័កកេ

**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

យ៉ាំង តត់ថ: យ៉ូន:ក:ប៉ុរ៉េ ម៉ុនិណ៉ូ ច: ប៉ាទាំង

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

តាំង ប៉ាទ:ឡាញ់ជ:ន:ម:ហាំង សិរ៉:សា ន:មាមិ ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ**

សុវ៉ាន់ណ:មាលិកេ សុវ៉ាន់ណ:ប៉ាប់ព:តេ សុម:ន:កូដេ យ៉ូន:ក:ប៉ុរ៉េ

**នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ណាំម:ទាយ: ន:ទិយា ប៉ាញ់ច:ប៉ាទ:វ:រ៉ាំង ថាណាំង អ:ហាំង វ៉ន្ទាមិ ទូរ៉:តោ ។

## នមស្សការព្រះរតនត្រ័យ

**យោកប្បកោដីហិបិ អប្បមេយ្យំ កាលំករោន្តោ**

យ៉ូកាប់ប៉ាក់កោដីហិបិ អ:ប៉ាក់ម៉ៃយ៉ាំង កាឡាំង ក:រ៉ោនតោ

**អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ**

អៈតិទុកកៈរ៉ានិ ខេទាំង គៈតោ លោកៈហិតាយៈ នាថោ នៈមោ

**មហាការុណិកស្ស តស្ស, អសម្ពុទ្ធំ ពុទ្ធនិសេវិតំ**

មៈហាការ៉ុណិកាស់សៈ តៈសាក់ អៈសាំពុតធាំង ពុតធៈនិសេវិតាំង

**យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ**

យាំង ភៈវ៉ាភៈវាំង គ័ចឆ្ចូតិ ជីវៈលោកោ នៈមោ

**អវិជ្ជាទិក្កិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស,**

អៈវិជ្ជាទីកកិលេសៈជាឡាំង វិទធាំងសិណោ ធាំមៈវ៉ៈរីសសៈ តៈសាក់,

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បភុតីហិ**

គុណេហិ យ៉ូ សីលៈសៈម៉ាធិបញ្ញា វិមុតតិញ្ញាណណាប់បៈភុតីហិ

**យុត្តោ ខេត្តញ្ជនានំ កុសលត្ថិកានំ តមរិយសង្ឃំ**

យ៉ុតតោ ខេតតាញ់ជៈនាណាំង កុសៈឡាត់ថិកាណាំង តៈមៈរីយៈសាំងឃាំង

**សិរសា នមាមិ ។**

សិរ៉ៈសា នៈមាមិ ។

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ**

អ៊ិចចេវៈម៉ាច់ច័នតៈ នៈម៉ះសៈណើយាំង នៈម៉ះសៈម៉ាណោ រៈតៈន័តយាំង យាំង

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ**

ប៉ុញញ៉ាភិស័ទទាំង វិប៉ុឡាំង អៈឡាត់ថាំង តៈសានុភាវេនៈ ហៈត័នតៈរ៉ាយោ ។

ប្រែថាៈ ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល អោយបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមអោយកំចាត់បង់ អពមង្គលទាំងឡាយ

អោយចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកំលាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វាហោង ។

## បាលីសមាទានសីល៥

**ឱកាស មយំ[១] ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន**
អ៊ុកាសៈ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ តិសៈរ៉ៈណេនៈ
**សហ បញ្ចសីលានិ យាចាម[២] ។**
សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
ទុតិយ៉ាំប៉ុ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ
**តិសរណេន សហ បញ្ចសីលានិ យាចាម ។**
តិសៈរ៉ៈណេនៈ សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។
**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន**
ទុតិយ៉ាំប៉ុ មៈយ៉ាំង ភ័នតេ វិសុង វិសុង រ័កខៈណ័តថាយៈ តិសៈរ៉ៈណេនៈ
**សហ បញ្ចសីលានិ យាចាម ។**
សៈហៈ ប៉ាញ់ចៈសីឡានិ យាចាមៈ ។

---

១- បើសូត្រម្នាក់ឯងថា **អហំ ភន្តេ** (អៈហាំង ភ័នតេ) បើសូត្រគ្នាច្រើនថា **មយំ ភន្តេ** (មៈយ៉ាំង ភ័នតេ) ។

២- បើសូត្រម្នាក់ឯងថា **យាចាមិ** , បើសូត្រច្រើនគ្នាថា **យាចាម** ( យា ចា មៈ) ។

*ត្រង់ពាក្យថា:* (**អនុគ្គហំ កត្វា សីលំ ទេថ នោ[៣] ភន្តេ**)[៤]
អៈនុកគៈហាំង ក័តត្វា សីឡាំង តេថៈ ណូ ភ័នតេ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ ដង) ៚

## ♠ ទទួលត្រៃសរណគមន៍ ពីព្រះសង្ឃដូច្នេះថា:

**ពុទ្ធំ សរណំ គច្ឆាមិ** (ពុតធាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**ធម្មំ សរណំ គច្ឆាមិ** (ធាំមាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**សង្ឃំ សរណំ គច្ឆាមិ** (សាំងឃាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (ទុតិយាំបិ ពុតធាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (ទុតិយាំបិ ធាំមាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (ទុតិយាំបិ សាំងឃាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (តៈតិយាំបិ ពុតធាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (តៈតិយាំបិ ធាំមាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ)
**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (តៈតិយាំបិ សាំងឃាំង សៈរ៉ៈណាំង គ័ចឆ្ចាមិ) ។

---

៣- បើសូត្រម្នាក់ឯងថា **ទេថ មេ** (តេថៈ ម៉េ), បើសូត្រច្រើនគ្នាថា **ទេថ នោ** ។

៤- បាលីដែលមានអក្សរមូលតូចមាននៅក្នុងវង្វង់ក្រចកនេះកន្លែងខ្លះគេសូធ្យ, កន្លែងខ្លះគេមិនសូធ្យទេ, គេសូធ្យត្រឹមតែ **បញ្ចសីលានិ យាចាម** ប៉ុណ្ណោះ ។ បាលីសមាទានសីល៥នេះ មានច្រើនយ៉ាងទៅតាមទីកន្លែងដែលគេនិយមប្រើ ដូច្នេះ បើឃើញមានការខុសប្លែកគ្នាខ្លះ សូមមេត្តាកុំអាលច្រឡំថាគេខុសឬយើងខុសនោះដែរ ។

( ***តិសរណគ្គហនំ បរិបុណ្ណំ*** បាលីខ្លីនៅក្នុងរង្វង់ក្រចកនេះ ព្រះសង្ឃលោកស្វាធ្យាយទេ)

*ត្រង់នេះឧបាសក-ឧបាសិកា-ទាយក-ទាយិកា ទទួលឆ្លើយពីលោកថា* **អាម ភន្តេ** ( អាមៈ ភ័នតេ)

**តទៅនេះនឹងទទួលសីល ៥**

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

ប៉ាណាតិប៉ាតា វេរៈមៈនី សិក្ខាប៉ៈទាំង សៈម៉ាទិយាមិ

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

អៈទិននាទានា វេរៈមៈនី សិក្ខាប៉ៈទាំង សៈម៉ាទិយាមិ

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**

កាមេសុមិចឆាចារ៉ា វេរៈមៈនី សិក្ខាប៉ៈទាំង សៈម៉ាទិយាមិ

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**

មុសាវ៉ាទា វេរៈមៈនី សិក្ខាប៉ៈទាំង សៈម៉ាទិយាមិ

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**

សុរាមេរ៉ៈយៈម៉ាច់ជាប់ប៉ៈម៉ាទាត់ថាណា វេរៈមៈនី សិក្ខាប៉ៈទាំង សៈម៉ាទិយាមិ

**ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។** *(ឧបាសក-ឧបាសិក-ទាយក-ទាយិកា ត្រូវទទួលថា* **អាម ភន្តេ***)*

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ,(ត្រូវទទួលអនុមោទនាថា សាធុ បីដង) ។**

**ព្រះគុណម៉ែ**

កូនអើយចូលកូនអ្នកត្រង់ត្រាប់ ម្តាយនឹងសាសាប់សព្វសេចក្តី
អោយកូនបានយល់ទាំងប្រុសស្រី ដឹងទេថាអ្វីជាគុណម៉ែ ។
ពរពោះកូនស្ងួនកន្លងមក គំរប់យកប្រាំបួនខែ
ម៉ែចាញ់ស្តាំងស្តមក្អួតឥតល្ហែ កំលាំងប្រួលប្រែបាយមិនបាន ។

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេយោ ខលិតោ**

อุตตะมังเคนะ วันเตหัง ปาทะปังสุง วะรุตตะมัง พุตเถโย ขะลิโต

**ទោសោ ពុទ្ធោ ខមតុ តំ មមំ ៕**

โทโส พุตโธ ขะมะตุ ตัง มะมัง ฯ

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ចា ទុវិធំ វរំ ធម្មេយោ ខលិតោ**

อุตตะมังเคนะ วันเตหัง ธัมมัญจะ ทุวิธัง วะรัง ธัมเมโย ขะลิโต

**ទោសោ ធម្មោ ខមតុ តំ មមំ ៕**

โทโส ธัมโม ขะมะตุ ตัง มะมัง ฯ

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ចា ទុវិធោត្តមំ សង្ឃេយោ ខលិតោ**

อุตตะมังเคนะ วันเตหัง สังฆัญจะ ทุวิโธตตะมัง สังเฆโย ขะลิโต

**ទោសោ សង្ឃោ ខមតុ តំ មមំ ៕**

โทโส สังโฆ ขะมะตุ ตัง มะมัง ฯ

## សូត្រសូមខមាទោសសង្ខេបបែបសម្រាយ

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

# គាថាសុំនូវសេចក្តីសុខ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញញ៉ុង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ សាសៈណាំង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញញ៉ុង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ រាជាណូ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញញ៉ុង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ញាតៈយ៉ោ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញញ៉ុង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ប៉ាណិណោ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ**

អាកាស័តថា ចៈ ភុមម័តថា ទេវ៉ា នាគា មៈហិតធិកា ប៉ុញញ៉ុង ណូ

**អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។**

អៈនុម៉ូទាន់តុ ចិរ៉ាំង រ័កខាន់តុ ណូ សៈទា ។

# ទសទិសាសុ មេត្តាផរណៈ

## ការផ្សាយមេត្តាចំពោះសព្វសត្វក្នុងទិសទាំង ១០

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

สับเบ้ ปุ๊ริตถิม๊ายะ ทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ បុរិត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

สับเบ้ ปุ๊ริตถิม๊ายะ อะนุทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

สับเบ้ ทักขิณายะ ทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ ทักขิณายะ อะนุทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ ป๊าจ์ฉิม๊ายะ ทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ ป๊าจ์ฉิม๊ายะ อะนุทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ อุ๊ตตะร๊ายะ ทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ อุ๊ตตะร๊ายะ อะนุทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**

สับเบ้ โหตถิม๊ายะ ทิสายะ สัตตา อะเวรา สุขี โหนตุ

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ ។**

ស័បបេ៉ អ៊ុបប៉ះរិម៉ាយ: ទិសាយ: ស័តតា អ:វេរា សុខី ហោនតុ ។

*បាលីផ្សាយមេត្តាចំពោះសព្វសត្វក្នុងទិសទាំង ១០ នេះ មានសេចក្ដីដូចគ្នាដដែល* ។ ដោយហេតុនេះ ខ្ញុំកូណា-អាត្មាភាព ក៏ប្រែរួបរួមដោយខ្លីថា: " ពួកសត្វទាំងអស់ ក្នុងទិសបូពិ, ទិសអាគ្នេយ៍, ទិសទក្សិណ, ទិសនិរតី, ទិសបស្ចិម, ទិសពាយ័ព្យ, ទិសឧត្តរ, ទិសឦសាន, ទិសខាងក្រោម ទិសខាងលើ, សូមឱ្យជាសត្វមិនមានពៀរនឹងគ្នា សូមឱ្យមានតែសេចក្ដីសុខ ( ជានិច្ចនិរន្តរ៍តទៅ)" ។

## រួចផ្សាយមេត្តាមិនចំពោះទិសតទៅទៀតថា

**សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ,**

ស័បបេ៉ ស័តតា អ:វេរា ហោនតុ, សុខិតា ហោនតុ

**និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ,**

និទទុក្ខា ហោនតុ, អ:ព្យាប៉ាច់ឈា ហោនតុ, អ:នីឃា ហោនតុ,

**ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ**

ទីឃាយុកា ហោនតុ, អ:រោគា ហោនតុ, សាំប៉ាត់តីហិ

**សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។**

សាំម៉ាច់ឈ័នតុ, សុខី អាត់តាណាំង បះរិហះរ៉ន់តុ ។

*ប្រែថា:* "ពួកសត្វទាំងអស់ សូមកុំមានពៀរនឹងគ្នា, សូមឱ្យបានតែសេចក្ដីសុខ, ឱ្យបានប្រាសចាកទុក្ខ, កុំព្យាបាទគ្នា, កុំមានសេចក្ដីព្រួយចំបែង, សូមឱ្យមានអាយុវែង, កុំឱ្យមានរោគ, សូមឱ្យសម្រេចដោយសម្បត្តិទាំងឡាយ, សូមរក្សានូវខ្លួនឱ្យជាសុខ ( តរៀងទៅ) !" ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**

ទុកខាប់ប៉ាត់តា ចះ និទទុក្ខា ភ:យ៉ាប់ប៉ាត់តា ចះ និពភ:យា

**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

សោកាប់ប៉ាត់តា ចះ នីសសោកា ហោនតុ ស័បបេ៉បុិ ប៉ាណិណោ ។

*ប្រែថា:* "សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង!" ។ (មេត្តាធម៌នេះ ទាំងបព្វជិត ទាំងគ្រហស្ថ អាចផ្សាយបានដូចគ្នា មានគុណានិសង្សច្រើនណាស់) ។

## ធម៌តាំងសេចក្តីប្រាថ្នានិងឧទ្ទិសផល

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហាពោលគឺនិព្វាន ។ គ្រប់ជាន់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពានដល់ឋានថ្លៃថ្លា ។ សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧបជ្ឈា-យាចារ្យ គុណញាតកាប្រាំពីរសន្តាន ។ ជីនដូនជីតា រស់នៅក្តីណា លោកម្ចាស់ឋាន សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត ដល់ឋានផុតទុក្ខ ។ ខ្ញុំសូមប្រាថ្នា សច្ចៈវាចា តទៅខាងមុខ សូមមានបញ្ញាភ្លឺថ្លាមោះមុត ឆ្លងរួចផុតទុក្ខ ដល់និព្វានហោង ។

# បត្តិទានគាថា

# ធម៌ឧទ្ទិសកុសល

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា**
យំាង កិញ្ចិ កុសៈលៈកាំមុំាង កាត់ត័បពាំង កិរិយុំាង មៈមៈ កាយេនៈ វាចា

**មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ**
មៈនៈសា តិទៈសេ សុគៈតាំង កៈតាំង យ៉េ ស័តតា សាញ់ញិណោ អ័តថិ

**យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ**
យ៉េ ចៈ ស័តតា អៈសាញ់ញិណោ កៈតាំង ប៉ុញញ៉ៈផៈឡាំង ម៉ៃហាំង ស័បប៉េ

**ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ**
ភាគី ភៈវ៉ន្តុ តេ យ៉េ តាំង កៈតាំង សុវិទិតាំង ទិនណាំង ប៉ុញញ៉ៈផៈឡាំង

**មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ**
មៈយា យ៉េ ចៈ តាត់ថៈ នៈ ជាណាន់តិ ទេវ៉ា គាន់ត្វា និវេទៈយុង

**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា**

ស័បប៉េ លោកាំហិ យ៉េ ស័តថា ជីវីនតាហារះហេ តុកា

**មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**

មៈនុញញ៉ាំង ភោជៈណាំង ស័បប៉េ លៈភ័នតុ មៈមៈ ចេតៈសាតិ ។

## ចប់ធម៌នមស្សការ នៃគុណព្រះរតនៈត្រៃដូចខាងលើនេះ

**ពុទ្ធបូជា មហាតេជោ** បូជាព្រះធមិមានបញ្ញាច្រើន

**ធម្មបូជា មហាបញ្ញោ** បូជាព្រះធមិមានបញ្ញាច្រើន

**សង្ឃបូជា មហាធនំ** បូជាព្រះសង្ឃមានទ្រព្យសម្បត្តិច្រើន ។

♠ *សូមឱ្យសព្វសត្វទាំងឡាយ បានសេចក្ដីសុខគ្រប់ទិសទាំងឡាយ ដោយកិរិយារៀននូវព្រះធមិនេះ ។*

*Everybody should live in peace by the manner of this education.*

## បាលីថ្វាយចង្ហាន់ព្រះពុទ្ធរូប

សំរាប់បុគ្គលអ្នកយកចង្ហាន់ទៅដាក់ឧទ្ទិស( ថ្វាយចំពោះព្រះរូបស្នងព្រះអង្គ)

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ដង)

**ឥមំ សូបព្យញ្ជនសម្បន្នំ សាលីនំ ឱទនំ ឧទកំ វរំ ពុទ្ធស្ស បូជេមិ**[៥] ។

អ៊ិមុាំង សូបៈព្យាញ់ជៈណៈសាំប៉ាន់ណាំង សាឡីណាំង អោទៈណាំង អ៊ុទៈកាំង វ៉ៈរ៉ាំង ពុតធ័សសៈ បូជេមិ

---

៥ - ត្រង់ពាក្យថា "**បូជេមិ** " នោះជាឯកវចនៈ ប្រែថា " បូជា, ថ្វាយ, ជូន, ប្រគេន ។ បាលីមួយនេះគឺចាប់ពី **ឥមំ** ដល់ **បូជេមិ** នោះ សំរាប់អ្នកដែលយកចង្ហាន់នឹងវត្ថុផ្សេងៗមានទឹកជាដើម ទៅថ្វាយចំពោះព្រះពុទ្ធរូបត្រូវតែសូធ្យនូវបាលីខាងលើនេះ ដើម្បីឧទ្ទិសចំពោះគុណរបស់ព្រះអង្គដែលមាន មេត្តា ករុណា មុទិតា នឹង ឧបេក្ខា ចំពោះសព្វសត្វទាំងអស់ឥតមានរើសមុខសត្វណានោះឡើយ ។ បាលីខាងនេះ ដែរសំរាប់អ្នកដែលយកចង្ហាន់ទៅដាក់ថ្វាយ ព្រះពុទ្ធរូបស្នងព្រះអង្គនោះគឺត្រូវសូត្រនូវបាលីនេះតែម្ដង ចំពោះតែនរណាអ្នកយកទៅថ្វាយប៉ុណ្ណោះ ។ មុននិងថ្វាយ ឬ ប្រគេននូវវត្ថុទាំងនោះត្រូវតែ ថ្វាយបង្គំព្រះពុទ្ធរូបស្នងអង្គនោះ ៣ ដង ព្រមទាំងធ្វើនូវចិត្តឱ្យស្អាតផូរផង់បំផុត ទើបបានផលល្អទៅក្នុងអនាគតពិតប្រាកដ ។

*ប្រែថា:* ខ្ញុំព្រះករុណា សូមថ្វាយនូវបាយនឹងទឹក ព្រមទាំងម្ហូបក្រៀមនឹងម្ហូបទឹកដ៏ប្រសើរនេះ ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

# សេចក្ដីពន្យល់សង្ខេប

ការថ្វាយចង្ហាន់ព្រះពុទ្ធរូបនេះ មិនមែនចេះតែបូជាឱ្យតែបាន១នោះទេ ព្រោះការបូជានេះត្រូវធ្វើចិត្តឱ្យស្អាត ហើយនឹកចំពោះគុណរបស់ព្រះអង្គ ដែលជាអគ្គបុគ្គលដ៏ឆ្នើមក្នុងលោក ហេតុអ្វីក៏បានជាធ្វើយ៉ាងនេះ បើមានតែព្រះពុទ្ធរូប ដែលគេឆ្លាក់អំពីឈើក្ដី អំពីស៊ីម៉ង់ត៍ក្ដី ជាដើម ។ កាលណាបើយើងមានចិត្តគិតរបៀបនេះ មិនឱ្យឈ្មោះថា ជាអ្នកជឿចំពោះព្រះសម្មាសម្ពុទ្ធនោះឡើយ ។ បើតាមន័យដែលព្រះអង្គ បានសំដែងទុកនៅក្នុងគម្ពីរមង្គលភាគ ១ ចំពោះវក្កលិភិក្ខុ ដែលចង់ជួបព្រះពុទ្ធ១ក៏បានសំដែងប្រាប់ថា ម្នាលវក្កលិ បើអាវុសោនឹកតថាគត ចូរអ្នកប្រតិបត្តិនូវធម៌របស់តថាគត ក៏ដូចជាបានឃើញតថាគត, បើបានឃើញតថាគត ក៏ដូចជាបានឃើញនូវធម៌របស់តថាគតនោះដែរ ចូរអ្នកធ្វើចិត្តរបស់អ្នកឱ្យបានប្រពៃចុះ ។ ការរៀបរាប់មកដោយសង្ខេបប៉ុណ្ណេះ ទុកជាកូនគំនិតមួយឬទុកជាមគ្គដ៏តូចមួយសំរាប់ឱ្យមហាជនពិចារណា គឺការធ្វើបុណ្យនេះជនម្នាក់១សុទ្ធតែចង់បានផលល្អហើយទើបលះបង់នូវទ្រព្យរបស់ខ្លួនទោះបីថាតិចក្ដីច្រើនក្ដី ក៏ចង់បានផលដ៏វិសេសវិសាលតែម្យ៉ាងគត់ គ្មានចង់បានអ្វីក្រៅពីសេចក្ដីសុខនោះឡើយ កាលណាបើបានសេចក្ដីសុខ សេចក្ដីចំរើន នឹងកើតមានដល់ជនដែលបានប្រតិបត្តិល្អនោះពុំខាន ។

♠ អាត្មាភាព សង្ឃឹមថា ប្រជាពុទ្ធបរិស័ទជិតឆ្ងាយទាំងឡាយ ប្រាកដជាមានមេត្តាចិត្តដ៏ល្អចំពោះការសិក្សានូវព្រះធម៌នេះ ពិតជាមិនខាន ។ ព្រោះថា សត្វទាំងអស់ដែលកើតមកនៅលើភពផែនដីនេះ តែងតែជួបនូវកងទុក្ខទាំង ៤ គឺ: កើត, ចាស់, ឈឺ, ស្លាប់ ពិតប្រាកដមែន ឥតមាននរណាម្នាក់គេចផុតនោះដែរ ។

♠ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងសព្រហ្មកសូត្រ និង សោណនន្ទជាតកថា ការប្រតិបត្តិ ដោយសក្ការៈ និង ដោយការនមស្សការ ឈ្មោះថា ការទំនុកបំរុង ។ ព្រោះហេតុនោះ បណ្ឌិតត្រូវតែនមស្សការ ធ្វើសក្ការៈចំពោះមាតាបិតាទាំងឡាយនោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងដុសលាង ទឹកងូត និង ទឹកលាងជើងទាំងពីរនោះជាដើម ។

# បាលីវេរចង្ហាន់ថ្វាយចំពោះព្រះពុទ្ធរូប

**មយំ ភន្តេ ឥមានិ បដិមារូបានិ តំ ភគវន្តំ វិយ មញ្ញមានា បិណ្ឌបាតាទិសក្ការេ អភិបូជយាម ឧក្ខស្សន្តំ បត្តោ ហោមិ អនាគតេ កាលេ ។ ទុតិយម្បិ..... ។ តតិយម្បិ..... ។**

ប្រែថា: បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ បានកត់ចំណាំ នូវព្រះពុទ្ធរូប ព្រះបដិមានេះ ថាដូចជាកាលព្រះអង្គគង់ធរមាននៅឡើយ ខ្ញុំព្រះករុណាទាំងឡាយ សូមបូជានូវគ្រឿងសក្ការៈទាំងឡាយ មានចង្ហាន់បិណ្ឌបាតជាដើម ខ្ញុំព្រះករុណាទាំងឡាយ សូមឱ្យអស់ទៅនូវទីបំផុតនៃសេចក្តីទុក្ខ ពោលគឺព្រះនិព្វាន ព្វដ៏អនាគតទៅឯមុខនោះហោង ។ ជាគំរប់ ២ ដងផង ។ ជាគំរប់ ៣ ដងផង ... ។

## ពុទ្ធភាសិត

## ពាលា ហវេ នប្បសំសន្តិ ទានំ

ប្រែថា: បុគ្គលពាលទាំងឡាយមិនសរសើរនូវទានឡើយ ។

## អធិប្បាយថា

តាមធម្មតា មនុស្សពាលមិនដែលសរសើរនូវទាន គឺការឱ្យរបស់សប្បុរសជនណាសោះឡើយ ព្រោះជនជំពូកនេះ ជាអ្នកល្ងង់ខ្លៅអប្បឥតប្រាជ្ញាគ្មានការពិចារណាឱ្យវែងឆ្ងាយថា ទានដែលធ្វើទៅហើយជាការមានប្រយោជន៍នោះទេ ផ្ទុយទៅវិញបុគ្គលពាលតែងយល់ថា អ្នកធ្វើទានជាមនុស្សឥតចេះគិតពិចារណាចំពោះហេតុការណ៍ផ្សេងៗគឺការចាយ វាយទ្រព្យរបស់ខ្លួនឱ្យអ្នកដទៃទទេៗ គ្មានបានអ្វីមកវិញសោះ ។ ដោយមានការយល់យ៉ាងនេះហើយ ទើបគេហៅថា ជនពាល ។ ជនជំពូកនេះតែងធ្វើអាក្រក់ជាដើមជាដរាប ។

**បាលីវេរចំពោះភិក្ខុ** (សំរាប់ភិក្ខុចាប់ពី ២ ឬ ៣ អង្គ គេហៅថាគណៈ)

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ឧទ្ទេសភត្តំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស[៦] សីលវន្តស្ស[៧] ទេម តេ គុណវន្តានយោ ឥមំ (ឧទ្ទេសភត្តំ)[៨] អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ...។ តតិយម្បិ ...។**

ប្រែថា: បពិត្រព្រះករុណាដ៏ចំរើនទ្បើយ វិចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធមិ បានមកដោយធមិ កើតឡើងដោយធមិ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះលោកអ្នកដ៏មានគុណទាំងឡាយ មានមាតា និង

---

៦- បើមានរៀបភោជនាហារ ដែលខ្មែរយើងធ្លាប់ហៅថា ដង្វាយព្រះពុទ្ធរូបក្នុងទីនោះ ទើបដាក់បាលីថា " **ពុទ្ធប្បមុខស្ស** " នេះ បើមិនមានដង្វាយព្រះពុទ្ធរូបទេ កុំដាក់បាលីនេះឡើយ ។ ប៉ែកខាងសេចក្តីប្រែក៏ដូចគ្នានោះដែរ ។

៧ - ត្រង់ពាក្យថា "**សង្ឃស្ស** " ប្រែថា ភិក្ខុសង្ឃៗនេះគឺចាប់ ៤ ឬ ៥ អង្គ ទើបគេហៅថា សង្ឃ។ បើមានតែ ២ ឬ ៣ អង្គ គេហៅថា គណៈ ឬ ក្រុម, បន , បើតាមបាលីថា **សីលវន្តានំ** ប្រែថា ដល់លោកម្ចាស់អ្នកមានសីលទាំងឡាយ, **សីលវន្តស្ស** ប្រែថា ដល់លោកម្ចាស់អ្នកមានសីល ។

៨- ត្រង់បទថា " **ឥត្តន្តាមំ** " ត្រូវបញ្ចូលឈ្មោះ "**ភត្ត**" តាមប្រាថ្នាយ៉ាងដូចជា " **សង្ឃភត្ត**" បញ្ចូលថា " **សង្ឃភត្តំ** " ប្រែថា (នូវភត្តដើម្បីសង្ឃ ឬថា នូវសង្ឃភត្ត ) បើជាគណៈត្រូវដាក់បាលីថា " **ឧទ្ទេសភត្តំ** " ប្រែថា " វេរនូវភត្តដល់ភិក្ខុមួយអង្គ ឬ ពីរអង្គ ឬថា ៣ អង្គ ជាដើម ទើបលោកហៅថា ឧទ្ទេសភត្ត គឺលោកអ្នកចាត់ចែងផ្នែកខាងសង្ឃ ដែលពុទ្ធបរិស័ទបាននិមន្តមកតែ ១ អង្គ ឬ ២ អង្គ ឬថា ៣ អង្គ ប៉ុណ្ណោះ ។

បិតាជាដើម យើងខ្ញុំទាំងឡាយវេរ (នូវឧទ្ទេសភត្ត)នេះ ព្រមទាំងបរិក្ខារ ប្រគេនដល់លោកម្ចាស់អ្នកមានសីល មានព្រះពុទ្ធ (រូបស្នងអង្គ) ជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិង បិតាជាដើមនោះ សំគាល់ (នូវឧទ្ទេសភត្ត)នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះលុះអនុមោទនារួចហើយ សូមឱ្យរួចរំដោះចាកទុក្ខទាំងពួង ឱ្យបានសម្រេច ដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏គុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនមកមិនដាច់នេះហោង ។ អស់វារៈ ២ ដងផង...។ អស់វារៈ៣ដងផង ។

♠ ខ្ញុំព្រះករុណា អាត្មាភាព សូមអភ័យទោសអំពីសំណាក់វិទូជិតឆ្ងាយទាំងឡាយ ចំពោះពាក្យពេចន៏,អក្ខរៈ, ឃ្លា, ល្បះ ដែលមិនសមគួរនិងមានការខ្វះខាតនូវចំណុចណានោះ សូមមេត្តាជួយកែចែកទានដោយអនុគ្រោះផង ខ្ញុំព្រះករុណា អាត្មាភាព សរសេរនូវធមិនមស្សការនេះ ដើម្បីជំនួយដល់ជាតិខ្មែរអ្នករៀនដំបូង ឬ ជាមគ្គដ៏តូចប៉ុណ្ណោះ ។

# ចប់ធមនមស្សការព្រះរតនៈត្រៃ